THE SCHOOL DISTRICT OF PHILADELPHIA

ការិយាល័យអគ្គនាយកក្រសួងអប់រំ
440 North Broad Street
Philadelphia, PA 19130

**William R. Hite, Jr., Ed.D.**
អគ្គនាយកក្រសួងអប់រំ

ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០២២

ជូនចំពោះ មាតាបិតា និងក្រុមគ្រួសារ របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

**ការស្ទង់មតិទូទាំងក្រសួងប្រចាំឆ្នាំ បើកហើយឥឡូវនេះ!** ការស្ទង់មតិទូទាំងក្រសួង គឺជាមធ្យោបាយដ៏ល្អបំផុតមួយ ក្នុងចំណោមមធ្យោបាយផ្សេងៗដែលយើងមាន ដើម្បីប្រមូលមតិកែលម្អពីលោកអ្នក និងវាយតម្លៃទស្សនៈរបស់លោកអ្នកលើប្រធានបទផ្សេងៗដែលជះឥទ្ធិពលដល់បទពិសោធន៍នៃការអប់រំសម្រាប់សិស្សានុសិស្ស។ ការឆ្លើយតបរបស់លោកអ្នក រួមជាមួយនឹងការឆ្លើយតបពីការស្ទង់មតិសិស្ស និងបុគ្គលិកសាលារបស់យើង ជួយយើងវាស់វែងនូវការរីកចម្រើនទៅកាន់ គោលដៅ និងការគាំទ្រ របស់ក្រុមប្រឹក្សាអប់រំ (Board of Education's Goals & Guardrails) និងកែលម្អសាលា និងសេវាកម្មរបស់យើង ដោយជូនដំណឹងអំពីផែនការសាលា និងអាទិភាពនៃការផ្តល់ប្រាក់ប្រចាំឆ្នាំ បញ្ជាក់ពីធនធានសហគមន៍ដែលសិស្សានុសិស្ស និងក្រុមគ្រួសារត្រូវការ និងអ្វីៗជាច្រើនទៀត។

ឆ្នាំនេះ មាតាបិតា និងអាណាព្យាបាល មានជម្រើសក្នុងការបំពេញការស្ទង់មតិ មាតាបិតា/អាណាព្យាបាល ដែលចំណាយពេល ១០ នាទី តាមសំបុត្រ ឬ តាមអ៊ិនធ័រណិត។ ច្បាប់ចម្លងសម្រាប់ការស្ទង់មតិតាមការបំពេញក្រដាស នឹងទៅដល់អាស័យដ្ឋានដែលមាននៅក្នុងឯកសារសាលារបស់កូនលោកអ្នកក្នុងរយៈពេលពីរសប្តាហ៍ក្រោយ។ ប្រសិនបើលោកអ្នកជ្រើសរើសបំពេញក្រដាស គ្រាន់តែដាក់ការស្ទង់មតិដែលបានបំពេញរួចទៅក្នុងស្រោមសំបុត្រដែលបានបង់ថ្លៃតែមរួចហើយ ហើយផ្ញើវាមកយើងវិញ – មិនចាំបាច់បិទតែមទេ! ប្រសិនបើលោកអ្នកចង់បំពេញការស្ទង់មតិតាមអ៊ិនធ័រណិត លោកអ្នកអាចចុចចូល ត្រង់នេះ។ លោកអ្នកនឹងត្រូវការអត្តលេខរបស់សិស្សលោកអ្នក ដែលមាននៅលើរបាយការណ៍ពិន្ទុរបស់ពួកគេ ហើយដូចគ្នានឹងលេខសម្រាប់អាហារថ្ងៃត្រង់របស់ពួកគេ។ ដើម្បីបង្ហាញការដឹងគុណរបស់យើង អ្នកណាម្នាក់ដែលបំពេញការស្ទង់មតិតាមអ៊ិនធ័រណិត នឹងត្រូវបានបញ្ចូលឈ្មោះដោយស្វ័យប្រវត្តិក្នុងការចាប់ឆ្នោតរង្វាន់ប្រចាំសប្តាហ៍ ដើម្បីមានឱកាសឈ្នះប័ណ្ណអំណោយអេឡិចត្រូនិចចំនួន ២៥ ដុល្លារ។

**រយៈពេលនៃការស្ទង់មតិទូទាំងក្រសួងនឹងបិទនៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០២២។** មិនថាលោកអ្នកសម្រេចចិត្តបំពេញការស្ទង់មតិដោយវិធីណាទេ ការឆ្លើយតបរបស់លោកអ្នកនឹងត្រូវរក្សាទុកជាសម្ងាត់។ ប្រសិនបើលោកអ្នកមានបញ្ហាក្នុងការចុចចូល ឬមានសំណួរអំពីការស្ទង់មតិ សូមផ្ញើអ៊ីមែលទៅកាន់ក្រុមស្ទង់មតិ តាមរយៈ schoolsurveys@philasd.org។ ដើម្បីជ្រាបព័ត៌មានបន្ថែមអំពីការស្ទង់មតិទូទាំងក្រសួង រួមទាំងលទ្ធផលកាលពីឆ្នាំមុន សូមចូលមើលគេហទំព័រ www.philasd.org/DWS។

ខ្ញុំសូមឱ្យលោកអ្នកឆក់យកអត្ថប្រយោជន៍ពីឱកាសនេះ ដើម្បីបញ្ចេញមតិរបស់លោកអ្នកឱ្យគេដឹងឮ ហើយសូមរំលឹកលោកអ្នកថា បច្ចុប្បន្ននេះក៏មានការស្ទង់មតិផ្សេងៗទៀតផងដែរ - រួមទាំង ការស្ទង់មតិអំពីថវិកា ឆ្នាំ២០២២ (2022 Budget Survey) និង ការស្ទង់មតិអំពីសំណើនៃកាលវិភាគសាលាសម្រាប់ឆ្នាំសិក្សា ២០២២-២០២៣ (2022-2023 Proposed Bell Schedule Survey) ដែលសុំមតិ និងមតិកែលម្អ ពីលោកអ្នក។ សូមអរគុណចំពោះការចូលរួមចំណែកជាមួយការរីកចម្រើននេះ!

ដោយសេចក្តីស្មោះស្ម័គ្រ



William R. Hite Jr., Ed.D.
អគ្គនាយកក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា